**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ១១៩ /ប្រក

ថ្ងៃ ពុធ ១ រោច ខែ ពិសាខ ឆ្នាំ កុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៩

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការគ្រប់គ្រងប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងប្រកាសលេខ១៤៥ ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍។

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.**

ប្រកាសនេះមានគោលបំណង៖

- ពង្រឹងការគ្រប់គ្រងការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ឱ្យមានប្រសិទ្ធភាព

ផ្ទះលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

- លើកកម្ពស់គុណភាពសេវាកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍
- បង្កើនទំនុកចិត្តដល់ប្រតិបត្តិករទេសចរណ៍ ភ្ញៀវទេសចរជាតិអន្តរជាតិ និងភាគីពាក់ព័ន្ធក្នុងការប្រកបអាជីវកម្មនិងប្រើប្រាស់សេវាកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍។

**ប្រការ២ ._**

ប្រកាសនេះ មានគោលដៅកំណត់វិធានគ្រប់គ្រងប្រាក់តម្កល់ធានាអាជីវកម្មរបស់ការីទេសចរណ៍ និង ភ្នាក់ងារទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ ._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ ._**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះ មានន័យដូចខាងក្រោមៈ

- **ការីទេសចរណ៍** (Tour Operators) សំដៅដល់បុគ្គលដែលរៀបចំ និងលក់ខ្សែទស្សនកិច្ចព្រមទាំងប្រមូលផ្តុំ សេវាកម្មទេសចរណ៍ផ្សេងៗទៀត សម្រាប់លក់ដោយផ្ទាល់ ឬតាមរយៈភ្នាក់ងារទេសចរណ៍ ឬភាគីផ្សេងទៀតក្នុងកិច្ចសន្យា
- **ការីទេសចរណ៍នាំភ្ញៀវចេញក្រៅប្រទេស** (Outbound Tour Operators) សំដៅដល់បុគ្គលដែលទទួលរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវទេសចរដែលមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៅកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា
- **ការីទេសចរណ៍នាំភ្ញៀវចូលក្នុងប្រទេស** (Inbound Tour Operators) សំដៅដល់បុគ្គលដែលទទួលរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវទេសចរនៅក្រៅប្រទេសចូលមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា
- **ការីទេសចរណ៍ក្នុងស្រុក** (Domestic Tour Operators) សំដៅដល់បុគ្គលដែលទទួលរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវទេសចរកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា
- **ភ្នាក់ងារទេសចរណ៍** (Travel Agent) សំដៅដល់បុគ្គលសញ្ជាតិខ្មែរដែលធ្វើអាជីវកម្មជាអ្នកជួយលក់សេវាកម្មទេសចរណ៍ ដូចជា សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មផ្សេងៗទៀតរាប់បញ្ចូលខ្សែទស្សនកិច្ចដែលបង្កើតដោយការីទេសចរណ៍ផងដែរ
- **ប្រាក់តម្កល់ធានាអាជីវកម្ម** សំដៅដល់ទឹកប្រាក់បម្រុងកាតព្វកិច្ចកំណត់ដោយក្រសួងទេសចរណ៍សម្រាប់ធានាអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ក្នុងធនាគារដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រងប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍ និង ភ្នាក់ងារទេសចរណ៍

**ប្រការ៥ .-**

ក្រសួងទេសចរណ៍ជាស្ថាប័នទទួលបន្ទុកគ្រប់គ្រងប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍ និង ភ្នាក់ងារទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៦ .-**

គ្មានបុគ្គលណាអាចប្រកបអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍បាន ដោយគ្មានការតម្កល់ប្រាក់ធានាអាជីវកម្មជាមុននោះទេ។

## ជំពូកទី៣
## នីតិវិធីនៃការគ្រប់គ្រងប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍ និង ភ្នាក់ងារទេសចរណ៍

**ប្រការ៧ .-**

ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មនៅធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា Foreign Trade Bank of Cambodia (FTB) ឬធនាគារដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍។

**ប្រការ៨ .-**

ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មទៅតាមប្រភេទអាជ្ញាបណ្ណទេសចរណ៍ដែលបានស្នើសុំដូចខាងក្រោម៖

ក. ការីទេសចរណ៍ដែលនាំភ្ញៀវទេសចរកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា (Outbound Tour Operators) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន៧០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក។

ខ. ការីទេសចរណ៍ដែលនាំភ្ញៀវទេសចរចូលកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Inbound Tour Operators) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន៥០០០(ប្រាំពាន់) ដុល្លារអាមេរិក។

គ. ភ្នាក់ងារទេសចរណ៍ (Travel Agent) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន៥០០០ (ប្រាំពាន់) ដុល្លារអាមេរិក។

ឃ. ការីទេសចរណ៍ដែលនាំភ្ញៀវទេសចរកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Domestic Tour Operators) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន២០០០(ពីរពាន់)ដុល្លារអាមេរិក។

ង. ភ្នាក់ងារទេសចរណ៍ក្នុងស្រុក (Domestic Travel Agent) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន ៥០០(ប្រាំរយ)ដុល្លារអាមេរិក។

ច. ចំពោះប្រតិបត្តិករទេសចរណ៍ដែលមានអាជ្ញាបណ្ណទេសចរណ៍ជាការីទេសចរណ៍ច្រើនប្រភេទ រួមមាន អាជ្ញាបណ្ណទេសចរណ៍ជាការីទេសចរណ៍ផង និងភ្នាក់ងារទេសចរណ៍ផង ស្ថិតក្រោមឈ្មោះតែមួយត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន៧០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក។

ឆ. ចំពោះសាខារបស់ការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍មិនតម្រូវឱ្យតម្កល់ប្រាក់ធានាអាជីវកម្មដោយឡែកឡើយ។

**ប្រការ៩ .-**

ប្រតិបត្តិករទេសចរណ៍ ដែលមានបំណងកែប្រែប្រភេទអាជីវកម្មជាការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ ឬបន្តអាជ្ញាបណ្ណទេសចរណ៍ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ៨នៃប្រកាសនេះ។



hb

## ជំពូកទី៤
## ការផ្លាស់ប្តូរនាមករណ៍ និង/ឬឈ្មោះម្ចាស់អាជីវកម្មការីទេសចរណ៍ និង ភ្នាក់ងារទេសចរណ៍

**ប្រការ១០.-**

ករណីមានការកែសម្រួល ឬផ្លាស់ប្តូរនាមករណ៍ក្រុមហ៊ុន ប្រតិបត្តិករទេសចរណ៍ត្រូវស្នើសុំការអនុញ្ញាតកែសម្រួល ឬផ្លាស់ប្តូរនាមករណ៍ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្មជាមុនសិន ហើយទើបអាចមកស្នើសុំកែសម្រួល ឬផ្លាស់ប្តូរនាមករណ៍ជំនួសនាមករណ៍ចាស់នៅក្រសួងទេសចរណ៍បាន។

ប្រសិនបើប្រតិបត្តិករទេសចរណ៍ស្នើសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មថ្មី ដោយមិនបានកែសម្រួល ឬផ្លាស់ប្តូរនាមករណ៍ក្រុមហ៊ុនលើអាជ្ញាបណ្ណទេសចរណ៍ចាស់ ការកែសម្រួល ឬផ្លាស់ប្តូរនាមករណ៍លើអាជ្ញាបណ្ណទេសចរណ៍មិនអាចអនុញ្ញាតបានទេ។

**ប្រការ១១.-**

ករណីប្តូរឈ្មោះម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ឬអ្នកគ្រប់គ្រង ប្រតិបត្តិករទេសចរណ៍ត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួនដូចខាងក្រោម៖

- លិខិតផ្ទេរ និងប្រគល់សិទ្ធិរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ឬអ្នកគ្រប់គ្រង
- កំណត់ហេតុនៃសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន ឬថ្នាក់ដឹកនាំស្តីពីការសម្រេចឱ្យបុគ្គលតំណាងក្រុមហ៊ុនដើម្បីគ្រប់គ្រងគណនីបន្តនៅធនាគារ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនមានសុពលភាព។

## ជំពូកទី៥
## ការដកប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍

**ប្រការ១២.-**

ប្រតិបត្តិករទេសចរណ៍អាចដាក់ពាក្យសុំដកប្រាក់តម្កល់ធានាអាជីវកម្មរបស់ខ្លួនវិញបាន ក្នុងករណីបិទអាជីវកម្មការីទេសចរណ៍ និង/ឬភ្នាក់ងារទេសចរណ៍។ ករណីនេះ ក្រសួងទេសចរណ៍នឹងពិនិត្យសម្រេចអនុញ្ញាតផ្តល់ឱ្យ៖

- លិខិតអនុញ្ញាតឱ្យបិទសកម្មភាពអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍
- លិខិតអនុញ្ញាតឱ្យដកប្រាក់តម្កល់ធានាអាជីវកម្មនេះវិញ។

ចំពោះបុគ្គលដែលបានដាក់ប្រាក់តម្កល់ធានាអាជីវកម្មរួចហើយ តែផ្លាស់ប្តូរមិនធ្វើអាជីវកម្មជាការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍អាចសុំដកប្រាក់តម្កល់វិញបាន ដោយត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងទេសចរណ៍ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់។ ក្រសួងទេសចរណ៍នឹងពិនិត្យសម្រេចផ្តល់លិខិតអនុញ្ញាតឱ្យដកប្រាក់តម្កល់ធានាអាជីវកម្មវិញតាមការស្នើសុំ។

**ប្រការ១៣.-**

ករណីមានពាក្យប្តឹង ឬការតវ៉ារបស់ភ្ញៀវ ឬប្រតិបត្តិករទេសចរណ៍ជាដៃគូ ឬសមត្ថកិច្ចពាក់ព័ន្ធចំពោះការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ទាក់ទងនឹងការបាត់បង់សម្ភារ ឬគ្រោះថ្នាក់ផ្សេងៗ ឬជំពាក់ប្រាក់ក្នុងដំណើរការអាជីវកម្ម ឬបញ្ហាពាក់ព័ន្ធនានា ហើយការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍នោះគេចវេះមិនព្រមចូលមកដោះស្រាយ ប្រាក់តម្កល់ធានាអាជីវកម្មនោះនឹងត្រូវបានដកដើម្បីដោះស្រាយបញ្ហាដែលមានការពាក់ព័ន្ធផ្សេងៗ។ ០៥ (ប្រាំ) ភាគរយនៃប្រាក់តម្កល់ធានាអាជីវកម្មដែលត្រូវបានដកនេះ ត្រូវចាត់ចែងសម្រាប់ទូទាត់ចំណាយក្នុងប្រតិបត្តិការតាមនីតិវិធីដោះស្រាយបញ្ហាពាក់ព័ន្ធផ្សេងៗ។

ការដកប្រាក់តម្កល់ធានាអាជីវកម្មនេះត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ១៤.-**

ក្រសួងទេសចរណ៍នឹងផ្សព្វផ្សាយតាមរយៈសារព័ត៌មានអំពីការតវ៉ារបស់ភ្ញៀវ ការបាត់បង់សម្ភារ ឬគ្រោះថ្នាក់ផ្សេងៗ ឬជំពាក់ប្រាក់ក្នុងដំណើរការអាជីវកម្ម ឬបញ្ហាពាក់ព័ន្ធនានា ដោយទុកឱសានវាទ ៣០ (សាមសិប)ថ្ងៃ សម្រាប់ទទួលពាក្យស្នើសុំការដោះស្រាយលើការបាត់បង់សម្ភារ ឬគ្រោះថ្នាក់ផ្សេងៗ ឬការជំពាក់ប្រាក់ ឬបញ្ហាពាក់ព័ន្ធនានាពីភាគីពាក់ព័ន្ធ។

## ជំពូកទី៦
## អវសានបញ្ញត្តិ

**ប្រការ១៥.-**

ប្រកាសលេខ១១២ ប្រក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍ ត្រូវចាត់ជានិរាករណ៍។

**ប្រការ១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ១៧.-**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គាធិការ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ និងប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូនៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីខេត្ត
- មន្ទីរទេសចរណ៍រាជធានីខេត្ត
- សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA)
- សមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា (PATA)
- ដូចប្រការ១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ